៤៥	លោកអនុសេនីយ៍ទោ	ញ៉ុក	សារិន	អត្តលេខ	១៤៣០៨
៤៦	លោកអនុសេនីយ៍ទោ	ហុក	សាគុយ	អត្តលេខ	១៤៨៧៨
៤៧	លោកអនុសេនីយ៍ទោ	ផឹង	មិន	អត្តលេខ	១៤២៩១
៤៨	លោកអនុសេនីយ៍ទោ	សែស	សុវណ្ណ	អត្តលេខ	១៧៩២៦
៤៩	លោកអនុសេនីយ៍ទោ	ព្រំ	សំអឿន	អត្តលេខ	១៤២៩២
៥០	លោកអនុសេនីយ៍ទោ	ប៊ូយ	ប៊ុណ្ណារិទ្ធ	អត្តលេខ	១៤៣៥១
៥១	លោកអនុសេនីយ៍ទោ	ជុំ	សាខន	អត្តលេខ	១៧៩៨៣
៥២	លោកអនុសេនីយ៍ទោ	ឃ្លោក	ប៊ុណ្ណារិទ្ធ	អត្តលេខ	១៤៣០៦
៥៣	លោកអនុសេនីយ៍ទោ	សម	សារុំ	អត្តលេខ	០៨៦៣៣
៥៤	លោកអនុសេនីយ៍ទោ	អ៊ូ	សុវណ្ណារិទ្ធ	អត្តលេខ	១៤៣៤៧
៥៥	លោកអនុសេនីយ៍ទោ	កៅ	ហ៊ី	អត្តលេខ	១៤៣០៧
៥៦	លោកអនុសេនីយ៍ទោ	ប៉ែន	សានឌី	អត្តលេខ	១១៤៧៩
៥៧	លោកអនុសេនីយ៍ទោ	ជាតិ	ម៉េងឡាយ	អត្តលេខ	១៥៣៩៤
៥៨	លោកអនុសេនីយ៍ទោ	ឃុយ	ងីហេង	អត្តលេខ	១៥៣៩៦
៥៩	លោកអនុសេនីយ៍ទោ	ចក់	សុខកៅ	អត្តលេខ	១៥៤១៩
៦០	លោកអនុសេនីយ៍ទោ	លាង	ស៊ីណាត	អត្តលេខ	១៥៤៤៣
៦១	លោកអនុសេនីយ៍ទោ	ធូ	វណ្ណៈ	អត្តលេខ	១៥៤៥៣
៦២	លោកអនុសេនីយ៍ទោ	ទ្រី	ប៊ុនធឿន	អត្តលេខ	១៥៤៤៨
៦៣	លោកអនុសេនីយ៍ទោ	មុំក	បារី	អត្តលេខ	១៩១៥៣
៦៤	លោកអនុសេនីយ៍ទោ	លាង	អេង	អត្តលេខ	០៣៨៦៤
៦៥	លោកអនុសេនីយ៍ទោ	សំ	ណាល់	អត្តលេខ	១៥៤២៧
៦៦	លោកអនុសេនីយ៍ទោ	ប្រាក់	សាគុណ	អត្តលេខ	១៥៤០២
៦៧	លោកអនុសេនីយ៍ទោ	គីម	ជីវន្ត	អត្តលេខ	១៥៤១៥
៦៨	លោកអនុសេនីយ៍ទោ	ហេង	ម៉ារ៉ែន	អត្តលេខ	១១៤៩៣
៦៩	លោកអនុសេនីយ៍ទោ	គីមុ	ឡោម	អត្តលេខ	២៤៨៩៧
៧០	លោកអនុសេនីយ៍ទោ	ប៉ាវ	វិចិត្រ	អត្តលេខ	១៦០០០
៧១	លោកអនុសេនីយ៍ទោ	កែវ	នារ៉ាភី	អត្តលេខ	១៥៣៨៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧២	លោកអនុសេនីយ៍ទោ	សូ	សារ៉ាត់	អត្តលេខ	១៩៩១៣
៧៣	លោកអនុសេនីយ៍ទោ	សុខ	សុវណ្ណ	អត្តលេខ	០៩៤៩៩
៧៤	លោកអនុសេនីយ៍ទោ	ម៉ា	ចិន្តា	អត្តលេខ	១៩៣៧៩
៧៥	លោកអនុសេនីយ៍ទោ	ស្រ៊ាង	អូន	អត្តលេខ	៤៧៩៩២
៧៦	លោកអនុសេនីយ៍ទោ	ស៊ុក	សូល	អត្តលេខ	១៩៣២៣
៧៧	លោកអនុសេនីយ៍ទោ	សែម	សុគន្ធា	អត្តលេខ	១៩៤៣៤
៧៨	លោកអនុសេនីយ៍ទោ	នាង	ណារិន	អត្តលេខ	១៩៩៦៦
៧៩	លោកអនុសេនីយ៍ទោ	សេង	ណា	អត្តលេខ	១៩២៧៨
៨០	លោកអនុសេនីយ៍ទោ	ហុង	គីមហឿន	អត្តលេខ	២៤៨៦៧
៨១	លោកអនុសេនីយ៍ទោ	សុខ	សាវន្ត	អត្តលេខ	៤៨២៤៤
៨២	លោកអនុសេនីយ៍ទោ	ប៊ិន	ប៊ុនថា	អត្តលេខ	១៩៩៧៣
៨៣	លោកអនុសេនីយ៍ទោ	លី	គីមឡេង	អត្តលេខ	១៩៤៣៧
៨៤	លោកអនុសេនីយ៍ទោ	អាន	គីមស្រ៊ី	អត្តលេខ	១៩៤៣៩
៨៥	លោកអនុសេនីយ៍ទោ	ខ្លូង	សុខុន	អត្តលេខ	១៣៦៧៦
៨៦	លោកអនុសេនីយ៍ទោ	ពុំ	កាន់	អត្តលេខ	១៣៦៨៩
៨៧	លោកអនុសេនីយ៍ទោ	ដៃ	សេងហ៊ាង	អត្តលេខ	១៣៨៩១
៨៨	លោកអនុសេនីយ៍ទោ	ឯក	ស៊ាងហ៊ន	អត្តលេខ	១៣៧៤៦
៨៩	លោកអនុសេនីយ៍ទោ	សេង	សាវ៉ន	អត្តលេខ	១៣៧៨១
៩០	លោកអនុសេនីយ៍ទោ	តក	សុផល	អត្តលេខ	១៦៦០៦
៩១	លោកអនុសេនីយ៍ត្រី	តែ	ឆុន	អត្តលេខ	២៧៨១៩
៩២	លោកអនុសេនីយ៍ត្រី	ឈន	ទ្រឿន	អត្តលេខ	១៧៨៦២
៩៣	លោកអនុសេនីយ៍ត្រី	ផាន	ផល	អត្តលេខ	២៤៦០៩
៩៤	លោកអនុសេនីយ៍ត្រី	ហ៊ុង	សុវណ្ណារិទ្ធ	អត្តលេខ	១៧៨៩៦

ឃ.គ្រឿងឥស្សរិយយស ការពារជាតិថ្នាក់ប្រាក់ ០៦ គ្រឿងចំពោះ :

១	លោកអនុសេនីយ៍ឯក	ម៉ែន	ហេងទិត	អត្តលេខ	១១១០៦
២	លោកអនុសេនីយ៍ឯក	ពេង	ស៊ីណូ	អត្តលេខ	១៣០៦៩
៣	លោកអនុសេនីយ៍ទោ	ប្រាក់	សុខជឿន	អត្តលេខ	១៩៥០៧
៤	លោកអនុសេនីយ៍ទោ	សិទ្ធ	សៅរ៉ៃ	អត្តលេខ	១៩៤៦៦
៥	លោកអនុសេនីយ៍ទោ	ហែម	ស៊ាងហ៊ន	អត្តលេខ	១៩៤៩៨
៦	លោកអនុសេនីយ៍ទោ	គន្ធ	ឡាយ	អត្តលេខ	១៩៩១៩
៧	លោកអនុសេនីយ៍ទោ	ច័ន្ទ	រិទ្ធី	អត្តលេខ	១៩៩៤៩
៨	លោកអនុសេនីយ៍ទោ	អ៊ិន	លីមហៀង	អត្តលេខ	១៩៩៩០

ខ.គ្រឿងឥស្សរិយយស ការពារជាតិថ្នាក់សិរិឆ្នី ០១ គ្រឿងចំពោះ :

១	លោកអនុសេនីយ៍ទោ	សុខ	ដារ៉ា	អត្តលេខ	០៩៧៥៨
២	លោកអនុសេនីយ៍ទោ	អាត	សុគន្ធ	អត្តលេខ	២០៣៤៨
៣	លោកអនុសេនីយ៍ទោ	វ៉ុត	នីម	អត្តលេខ	១៤៤៩២
៤	លោកអនុសេនីយ៍ទោ	អ៊ុង	តិន	អត្តលេខ	១៤៤៩០
៥	លោកអនុសេនីយ៍ទោ	ឈូក	ស្រស់	អត្តលេខ	១៤៤៧០
៦	លោកអនុសេនីយ៍ទោ	ទេព	ឆុន	អត្តលេខ	១៤៥៣០
៧	លោកអនុសេនីយ៍ទោ	វង	សុខន	អត្តលេខ	១៤៥២៣
៨	លោកអនុសេនីយ៍ទោ	ភួង	ផេង	អត្តលេខ	១៤៥៣១
៩	លោកអនុសេនីយ៍ទោ	ឃីម	សុវណ្ណ	អត្តលេខ	១៤៥២៩
១០	លោកអនុសេនីយ៍ទោ	សេន	គីមសាន	អត្តលេខ	១៤៥២៦
១១	លោកអនុសេនីយ៍ទោ	សៀង	ឃុនលី	អត្តលេខ	១៤៥៣៥
១២	លោកអនុសេនីយ៍ទោ	នាង	សារិន	អត្តលេខ	១៤៥៥៩
១៣	លោកអនុសេនីយ៍ទោ	អឿន	អ៊ីម	អត្តលេខ	១៤៥៥៦
១៤	លោកអនុសេនីយ៍ទោ	ឆន	ជា	អត្តលេខ	១៤៥៦២
១៥	លោកអនុសេនីយ៍ទោ	ជ័យ	សុវណ្ណ	អត្តលេខ	១៤៥៥៧
១៦	លោកអនុសេនីយ៍ទោ	ញ៉ឹប	សុផល	អត្តលេខ	១៤៥៦១
១៧	លោកអនុសេនីយ៍ទោ	ជឹម	ជឿន	អត្តលេខ	១៤៥៥៨
១៨	លោកអនុសេនីយ៍ទោ	ម៉ិច	មឿន	អត្តលេខ	១៤៥៦៤
១៩	លោកអនុសេនីយ៍ទោ	នៅ	ថុន	អត្តលេខ	១៤៥៦៥
២០	លោកអនុសេនីយ៍ទោ	ផន	ស៊ីផៃ	អត្តលេខ	១៤៥៦៣
២១	លោកអនុសេនីយ៍ទោ	ហុក	ហេង	អត្តលេខ	១៤៥៧១
២២	លោកអនុសេនីយ៍ទោ	កែប	ប៊ុនធឿន	អត្តលេខ	១៤៥៧២
២៣	លោកអនុសេនីយ៍ទោ	អ៊ូន	ឆុន	អត្តលេខ	១៤៥៧៥
២៤	លោកអនុសេនីយ៍ទោ	វន	ឡេង	អត្តលេខ	១៤៥៦៩
២៥	លោកអនុសេនីយ៍ទោ	អ៊ុក	ឈឿន	អត្តលេខ	១៤៥៧០
២៦	លោកអនុសេនីយ៍ទោ	ឯម	សាម៉េន	អត្តលេខ	១៤៥៧៧
២៧	លោកអនុសេនីយ៍ទោ	កែវ	សុភ័ក្ត្រ	អត្តលេខ	១៤៥៣៩
២៨	លោកអនុសេនីយ៍ទោ	នៅ	ណន	អត្តលេខ	១៤៥៣៨
២៩	លោកអនុសេនីយ៍ទោ	វ៉ាយ	សុផាត	អត្តលេខ	១៤៥៤០
៣០	លោកអនុសេនីយ៍ទោ	សុខ	សុភក្តិ	អត្តលេខ	១៤៤៧៧
៣១	លោកអនុសេនីយ៍ទោ	តួយ	វ៉ាន់ថន	អត្តលេខ	១៤៤៩៦

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣២	លោកអនុសេនីយ៍ទោ	កង	ចាន់ឌី	អត្តលេខ	១៤៥០២
៣៣	លោកអនុសេនីយ៍ទោ	នួន	ឡឿន	អត្តលេខ	១៤៥០១
៣៤	លោកអនុសេនីយ៍ទោ	ឃុន	ជា	អត្តលេខ	១៤៥០៧
៣៥	លោកអនុសេនីយ៍ទោ	ហែម	ឈូរ៉ា	អត្តលេខ	១៤៥០៤
៣៦	លោកអនុសេនីយ៍ទោ	ជា	សំប៊ី	អត្តលេខ	២២៩៣៥
៣៧	លោកអនុសេនីយ៍ទោ	មាស	សារិន	អត្តលេខ	១៤៥០៩
៣៨	លោកអនុសេនីយ៍ទោ	សុខ	វណ្ណសុត	អត្តលេខ	១៤៥១១
៣៩	លោកអនុសេនីយ៍ទោ	សែត	សឿន	អត្តលេខ	១៤៥១២
៤០	លោកអនុសេនីយ៍ទោ	ម៉ែត់	វ៉ាន់ហាន	អត្តលេខ	១៤៥២១
៤១	លោកអនុសេនីយ៍ទោ	ពេជ្រ	សុខា	អត្តលេខ	១៤៥១៨
៤២	លោកអនុសេនីយ៍ទោ	គង់	គីន	អត្តលេខ	១៤៥១៤
៤៣	លោកអនុសេនីយ៍ទោ	មាស	សំអឿន	អត្តលេខ	១៤៥១៣
៤៤	លោកអនុសេនីយ៍ទោ	សយ	ពុជ	អត្តលេខ	១៤៤៦២
៤៥	លោកអនុសេនីយ៍ទោ	រៃ	ឈន	អត្តលេខ	១៤៥១៦
៤៦	លោកអនុសេនីយ៍ទោ	ឃីម	ឃន	អត្តលេខ	១៤៥៤៣
៤៧	លោកអនុសេនីយ៍ទោ	ជឹម	ប៊ុនធី	អត្តលេខ	១៤៥៤៤
៤៨	លោកអនុសេនីយ៍ទោ	ទឹម	តុន	អត្តលេខ	១៤៥៤៨
៤៩	លោកអនុសេនីយ៍ទោ	តា	នៅ	អត្តលេខ	១៤៥៤៦
៥០	លោកអនុសេនីយ៍ទោ	ខៀវ	សន	អត្តលេខ	១៤៥៤៩
៥១	លោកអនុសេនីយ៍ទោ	ខេង	ចាន់ថុល	អត្តលេខ	១៤៥៥១
៥២	លោកអនុសេនីយ៍ទោ	ជា	ធី	អត្តលេខ	១៤៥៥២
៥៣	លោកអនុសេនីយ៍ទោ	ខៃ	ខឿន	អត្តលេខ	១៤៥៥៣
៥៤	លោកអនុសេនីយ៍ទោ	ផេង	ម៉ែត	អត្តលេខ	១៤៤៥៤
៥៥	លោកអនុសេនីយ៍ទោ	ស៊ុយ	សុខេង	អត្តលេខ	១៤៤៥៧
៥៦	លោកអនុសេនីយ៍ទោ	គីម	កន	អត្តលេខ	១៩៤៥៥
៥៧	លោកអនុសេនីយ៍ទោ	សួង	ចាន់ថន	អត្តលេខ	១៩៤៥៦
៥៨	លោកអនុសេនីយ៍ទោ	ចេង	ស៊ីថា	អត្តលេខ	១៩៤៥៧
៥៩	លោកអនុសេនីយ៍ទោ	ហង្ស	សារឿន	អត្តលេខ	១៤៤៥៨
៦០	លោកអនុសេនីយ៍ទោ	ឃុន	សុខឃីម	អត្តលេខ	២២៩៦៤
៦១	លោកអនុសេនីយ៍ទោ	សៀង	សារ៉េត	អត្តលេខ	២២៨២៧
៦២	លោកអនុសេនីយ៍ទោ	អ៊ុក	សុផា	អត្តលេខ	១០៦៤៥
៦៣	លោកអនុសេនីយ៍ទោ	ប្រាក់	ប៊ុនឡៃ	អត្តលេខ	២២៩៦៥

ROYAUME DU CAMBODGE
LE MINISTRE ... PALAIS ROYAL
ព្រះបរមរាជវាំង

៦៤	លោកអនុសេនីយ៍ទោ	ហែម	សុខន	អត្តលេខ	១៩៥២៣
៦៥	លោកអនុសេនីយ៍ទោ	ធឿង	ឡឿង	អត្តលេខ	១៩៤៥០
៦៦	លោកអនុសេនីយ៍ទោ	ម៉ែត	ដា	អត្តលេខ	១៩៤៩៧
៦៧	លោកអនុសេនីយ៍ទោ	ផេន	ខ្លា	អត្តលេខ	២៣១០៣
៦៨	លោកអនុសេនីយ៍ទោ	ស៊ុម	ស៊ុនលី	អត្តលេខ	១៤៥០៣
៦៩	លោកអនុសេនីយ៍ទោ	ជា	ជូន	អត្តលេខ	១៤៤៨៧
៧០	លោកអនុសេនីយ៍ទោ	យិន	សុវណ្ណរិទ្ធ	អត្តលេខ	១៩៥៥៣
៧១	លោកអនុសេនីយ៍ត្រី	ស៊ុម	ងួនលី	អត្តលេខ	២៣០៨៣
៧២	លោកអនុសេនីយ៍ត្រី	ម៉ម	សំអុល	អត្តលេខ	២២៩០៦
៧៣	លោកអនុសេនីយ៍ត្រី	ណយ	សារិទ្ធ	អត្តលេខ	១៩៤៣៧
៧៤	លោកអនុសេនីយ៍ត្រី	សួង	សាម៉េត	អត្តលេខ	១៩៤៤១
៧៥	លោកអនុសេនីយ៍ត្រី	ជាត	ផល្លី	អត្តលេខ	២២៩២៩
៧៦	លោកអនុសេនីយ៍ត្រី	យុន	វន	អត្តលេខ	២២៨៩៤
៧៧	លោកអនុសេនីយ៍ត្រី	ម៉ី	កុល	អត្តលេខ	១៩៥១៦
៧៨	លោកអនុសេនីយ៍ត្រី	ខួច	ភារិទ្ធ	អត្តលេខ	២៣២៩៥
៧៩	លោកអនុសេនីយ៍ត្រី	ឡាំង	ផល្លារុណ	អត្តលេខ	១៩៤៩៨
៨០	លោកអនុសេនីយ៍ត្រី	អ៊ុំ	រិន	អត្តលេខ	១៩៥០១
៨១	លោកអនុសេនីយ៍ត្រី	នួន	សុខ	អត្តលេខ	១៩៤៨៦
៨២	លោកអនុសេនីយ៍ត្រី	សេក	សំអឿន	អត្តលេខ	១៩៤៨២
៨៣	លោកអនុសេនីយ៍ត្រី	អោម	សំអុល	អត្តលេខ	១៩៤៩៣
៨៤	លោកអនុសេនីយ៍ត្រី	នួន	វណ្ណៈ	អត្តលេខ	២៣០៩៩
៨៥	លោកអនុសេនីយ៍ត្រី	នៅ	នូ	អត្តលេខ	១៩៥៦៥
៨៦	លោកអនុសេនីយ៍ត្រី	ម៉ែន	ពៅ	អត្តលេខ	១៩៥៣៦
៨៧	លោកអនុសេនីយ៍ត្រី	ពីរ	វេង	អត្តលេខ	២៣១៣១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.០៩០៤.៤២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៩៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៥/៤២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១០៥៥ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម ÷

- ឯកឧត្តម ម៉ក់ ជាលី
- ឯកឧត្តម សម ឫទ្ធិ

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៥០៤.៤២៥

លេខ : ៣៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៥

រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៥

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥/ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ហួន ចន្ទកក្កដា** អត្តលេខ ៥៤៩២៥ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០៤.៤៣០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៨៧ ច.ល
ជូនដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ ២០០៩ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម ខួន ញឹម ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .. ត្រូវបានតែងតាំង ឯកឧត្តម ឈៀង ស្វងហៀង ជាទីប្រឹក្សា ឯកឧត្តម ខួន ញឹម អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៤-មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា២ .. សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .. ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល. ០៩០៤.៤៣១

លេខ : ៤០៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុង ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៤០៩/៤២៩

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : - តម្លើងឋានៈជូនទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បន្ថែមលើមុខងារបច្ចុប្បន្ន ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម គីម សុផា មានឋានៈស្មើ រដ្ឋលេខាធិការ

២-ឯកឧត្តម ហ៊ី រួន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

- ផ្ទេរមុខងារ និងតម្លើងឋានៈជូន :

- ឯកឧត្តម ទីម ប៊ិន ពីជំនួយការមកជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤៧.០៩០៤.៤៣២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៤០១ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឱនភេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្តូរឈ្មោះ និងតម្លើងប្រតិបត្តិការអាកាសយានដ្ឋានកងកេង ទៅជាអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ស ម្រេ ច

មាត្រា ១ : ត្រូវបានប្តូរឈ្មោះ និងតម្លើងប្រតិបត្តិការអាកាសយានដ្ឋានកងកេង ទៅជា អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ចំណុះអគ្គនាយកដ្ឋានអាកាសចរស៊ីវិលនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

មាត្រា ២ : អាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- ធានាសុវត្ថិភាព ការហោះហើរ ចុះចតឱ្យអាកាសយានរបស់ក្រុមហ៊ុនអាកាសចរ ដែលកំពុងធ្វើសេវាកម្ម នៅអាកាសយានដ្ឋាន។
- អនុវត្តការងារត្រួតពិនិត្យ គ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ក្នុងបរិវេណទទួលខុសត្រូវរបស់ អាកាសយានដ្ឋាន។
- ការពារសន្តិសុខ សុវត្ថិភាព ក្នុង និងជុំវិញអាកាសយានដ្ឋាន ដោយអនុវត្តទៅតាមឧបសម្ព័ន្ធ ទី ១៧ របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។
- សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនធ្វើសេវាកម្ម ពាណិជ្ជកម្មផ្ទៃដី ក្នុងការបំរើភ្ញៀវ និងអាកាសយាន។
- សហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ដែលកំពុងបំពេញភារកិច្ចក្នុងអាកាសយានដ្ឋាន ដើម្បីអនុវត្តឱ្យ បានសំរេចនូវតួនាទីច្រកទ្វារត្រួតពិនិត្យអន្តរជាតិអាកាសយានដ្ឋាន។
- ត្រួតពិនិត្យ បូកសរុបការងារដឹកជញ្ជូនចេញ និងចូលតាមច្រកទ្វារអាកាសយានដ្ឋាន។

មាត្រា ៣ : អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ត្រូវបានដឹកនាំដោយនាយក ០១ រូប (ឋានៈស្មើប្រធាននាយកដ្ឋាន) និងមាននាយករង មួយចំនួន ជាជំនួយការ។

មាត្រា ៤ : ការរៀបចំតួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនិមួយៗ ចំណុះអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តាម ការឯកភាពពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា ៥ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អភិបាលខេត្តព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខា ធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ រាជធានីគ្រប់ខេត្តត្រូវទទួល បន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច* ✓
- *ដូចមាត្រា ៦*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៩០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាពនៅតាមក្រសួង ស្ថាប័ននានា ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពការងារ និងគណនេយ្យភាព ក្នុងការអនុវត្តឱ្យបានសម្រេចជោគជ័យនូវការងារអាទិភាពនៃក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ។

មាត្រា ២.-

កន្សោមអាទិភាព គឺជាក្រុមមន្ត្រីរាជការដែលត្រូវបានជ្រើសរើស ដើម្បីអនុវត្តឱ្យបានជោគជ័យនូវប្រតិបត្តិការអាទិភាព និងមានការទទួលខុសត្រូវចំពោះមុខថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ។

ជំពូកទី២

ការបង្កើតកន្សោមអាទិភាព

មាត្រា ៣.-

ក្រសួង ស្ថាប័ន ត្រូវកំណត់អត្តសញ្ញាណបេសកកម្មអាទិភាព ដោយផ្អែកលើឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការសកម្មភាពអភិបាលកិច្ច ។

កន្សោមអាទិភាព ត្រូវបានបង្កើតឡើង ដើម្បីបំពេញបន្ថែម និងពង្រឹងឧបករណ៍ប្រសិទ្ធភាពការងារផ្សេងៗ ដូចជា ទីភ្នាក់ងារប្រតិបត្តិការពិសេស និងការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ។

មាត្រា ៤.-

ក្រសួង ស្ថាប័ន ត្រូវរៀបចំដាក់សំណើ ស្តីពីការបង្កើតកន្សោមអាទិភាព មកគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ដើម្បីសុំការអនុមតិជាគោលការណ៍ ។

សំណើនៃការបង្កើតកន្សោមអាទិភាព ត្រូវមានការបញ្ជាក់ពី :

- សេចក្តីប្រកាសបេសកកម្ម
- លទ្ធផលរំពឹងទុក
- ចំនួនមុខតំណែង
- ចរិកាសម្រាប់ឧបត្ថម្ភសមាជិក
- កិច្ចសន្យាគ្រប់គ្រង និងកិច្ចសន្យាការងារ ។

មាត្រា ៥.-

បន្ទាប់ពីគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ពិនិត្យ និងអនុម័តលើសំណើស្តីពីការបង្កើតកន្សោមអាទិភាពរួចហើយ ក្រសួង ស្ថាប័នត្រូវរៀបចំឯកសារក្របខ័ណ្ឌដូចមានបញ្ជាក់នៅក្នុងឯកសារណែនាំស្តីពីការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំ ជ្រើសរើសមន្ត្រីរាជការទៅតាមនីតិវិធី និងតម្លាភាព ហើយត្រូវដាក់ស្នើបញ្ជីឈ្មោះមន្ត្រីដែលនឹងត្រូវតែងតាំងមកគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ដើម្បីពិនិត្យ និងអនុម័តជាចុងក្រោយ ។

មាត្រា ៦.-

ក្រោយពីទទួលបានការអនុម័តចុងក្រោយពីគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និង គណនេយ្យភាពរួចហើយ ក្រសួង ស្ថាប័ន ត្រូវដាក់ឱ្យអនុវត្តកន្សោមអាទិភាព ដូចខាងក្រោម ៖

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានមួយផ្នែកដោយថវិការួមរបស់បណ្តាដៃគូអភិវឌ្ឍន៍ រដ្ឋមន្ត្រី ឬ តំណាងក្រសួង ស្ថាប័ន ត្រូវចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយបណ្តាដៃគូអភិវឌ្ឍន៍ និងត្រូវចេញប្រកាសតែងតាំងមន្ត្រី ព្រមទាំងអនុម័តលើឯកសារណែនាំសម្រាប់អនុវត្ត និងដាក់ឱ្យដំណើរការកន្សោមអាទិភាព។

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានទាំងស្រុងដោយថវិកាជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវចេញប្រកាសតែងតាំងមន្ត្រី ព្រមទាំងអនុម័តលើឯកសារណែនាំសម្រាប់អនុវត្ត និងដាក់ឱ្យដំណើរការកន្សោមអាទិភាព។

ឯកសារណែនាំត្រូវរៀបរាប់ចែងលំអិតអំពីនីតិវិធី និងដំណើរការនៃការអនុវត្តកន្សោមអាទិភាពនីមួយៗ ស្របទៅតាមឯកសារណែនាំស្តីពីការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព ។

មាត្រា ៧.-

ការបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព នឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

ជំពូកទី៣

ទំហំ និងការជ្រើសរើសសមាជិកកន្សោមអាទិភាព

មាត្រា ៨.-

កន្សោមអាទិភាពនឹងត្រូវរៀបចំឡើងសម្រាប់មុខតំណែងដែលចាំបាច់ ដើម្បីសម្រេចគោលដៅ និងលទ្ធផលដែលបានគ្រោងទុក។

នៅពេលដែលមុខតំណែងកន្សោមអាទិភាពត្រូវបានបង្កើតឡើងសម្រាប់បំពេញបន្ថែមទៅលើមុខតំណែង

នៃការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ការបង្កើតមុខតំណែងនេះត្រូវផ្អែកលើការងារដែលទ្រទ្រង់ដល់ការបង្កើតមុខតំណែងសម្រាប់អនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

សមាជិកកន្សោមអាទិភាពត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នសាមី និងស្ថិតនៅក្នុងប្រភេទក្របខ័ណ្ឌ **ក ខ និង គ** ។

ការជ្រើសរើសសមាជិកកន្សោមអាទិភាព ត្រូវផ្អែកលើគុណៈសម្បត្តិស័ក្តិសម និងបទពិសោធន៍ការងារដែលបញ្ជាក់ច្បាស់លាស់នៅក្នុងតម្រូវការមុខតំណែង ។

មាត្រា ៩.-

ដំណើរការជ្រើសរើសសមាជិកកន្សោមអាទិភាព ត្រូវធ្វើឡើងដោយផ្អែកលើការវាយតម្លៃយ៉ាងសម្រិតសម្រាំង និងមានតម្លាភាព។ ការជ្រើសរើសត្រូវផ្អែកទៅលើតម្រូវការមុខតំណែង និងត្រូវធ្វើការប្រកាសផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងក្រសួង ស្ថាប័នសាមី ។

មាត្រា ១០.-

មន្ត្រីរាជការដែលត្រូវបានតែងតាំងជាសមាជិកកន្សោមអាទិភាព ត្រូវចុះកិច្ចសន្យាការងារ។ សមាជិកកន្សោមអាទិភាពដែលមិនអនុវត្តតាមកិច្ចសន្យាការងារ នឹងត្រូវបញ្ឈប់ពីសមាជិកភាពនៃកន្សោមអាទិភាព ។

មាត្រា ១១.-

ទំហំ និងសមាសភាពនៃកន្សោមអាទិភាពនីមួយៗ អាស្រ័យទៅលើតម្រូវការមុខងារប្រតិបត្តិការអាទិភាពដែលបានកំណត់ក្នុងបេសកកម្ម និងលទ្ធភាពនៃការធ្វើហិរញ្ញប្បទានពីថវិកាជាតិ និង/ឬ ពីបណ្តាដៃគូអភិវឌ្ឍន៍ សម្រាប់ចំណាយលើប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រីដែលត្រូវបានតែងតាំងជាសមាជិកកន្សោមអាទិភាព ។

មុខតំណែងកន្សោមអាទិភាពនីមួយៗ ត្រូវមានការពណ៌នាបញ្ជាក់អំពីមុខតំណែង តួនាទី ភារកិច្ច និងតម្រូវការសមត្ថភាពវិជ្ជាជីវៈ ។

ជំពូកទី៤

អត្ថប្រយោជន៍សម្រាប់សមាជិកកន្សោមអាទិភាព

មាត្រា ១២.-

សមាជិកកន្សោមអាទិភាពនឹងទទួលបាននូវអត្ថប្រយោជន៍ពីរយ៉ាង គឺ :

- ប្រាក់ឧបត្ថម្ភលើកទឹកចិត្តលើលទ្ធផលការងារប្រចាំខែ ដូចមានចែងក្នុងមាត្រា១៣ និងមាត្រា១៤
- មានអាទិភាពក្នុងឱកាសបណ្តុះបណ្តាលសម្រាប់ពង្រឹងការងារកន្សោមអាទិភាព និងការអភិវឌ្ឍន៍សមត្ថភាពផ្ទាល់ខ្លួន ។

សមាជិកកន្សោមអាទិភាព បន្តទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗដូចមន្ត្រីរាជការដទៃទៀតដែលបានកំណត់នៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ។

មន្ត្រីដែលបានតែងតាំងជាសមាជិកកន្សោមអាទិភាព នឹងមិនត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តពីគម្រោងផ្សេងៗទៀត ឡើយ ។

មាត្រា ១៣.-

សមាជិកកន្សោមអាទិភាពដែលបានបំពេញការងារគ្រប់លក្ខខ័ណ្ឌនៃកិច្ចសន្យាការងារ នឹងទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំខែ ដូចខាងក្រោម :

- ប្រភេទ ក ៥២០ ០០០ (ប្រាំរយម្ភៃពាន់) រៀល ក្នុងមួយខែ
- ប្រភេទ ខ ៤៥០ ០០០ (បួនរយហាសិបពាន់) រៀល ក្នុងមួយខែ
- ប្រភេទ គ ៣៥០ ០០០ (បីរយហាសិបពាន់) រៀល ក្នុងមួយខែ

មាត្រា ១៤.-

ប្រធានគម្រោងកន្សោមអាទិភាពនីមួយៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ៦០០ ០០០ (ប្រាំមួយរយពាន់) រៀល ក្នុងមួយខែ ហើយមិនអាចទទួលបានប្រាក់ឧបត្ថម្ភក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះបានឡើយ ។

មន្ត្រីនៅតាមក្រសួង ស្ថាប័ន ដែលកំពុងចាត់ចែងការបង្កើត ការគ្រប់គ្រង និងតាមដានត្រួតពិនិត្យគ្រប់កម្មវិធីកន្សោមអាទិភាពនៅក្នុងយុត្តាធិការរបស់ខ្លួន នឹងត្រូវបានទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តស្របតាមលក្ខខ័ណ្ឌនៃអនុក្រឹត្យនេះ ឬលក្ខខ័ណ្ឌនៃអនុក្រឹត្យ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

មាត្រា ១៥.-

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានទាំងស្រុងដោយថវិកាជាតិ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់សមាជិកកន្សោមអាទិភាព ត្រូវធ្វើឡើងតាមតារាងទូទាត់បៀវត្សរ៍តាមប្រព័ន្ធព័ត៌មានវិទ្យារបស់រាជរដ្ឋាភិបាល ។

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានមួយផ្នែកដោយថវិកាជាតិ និងមួយផ្នែកដោយថវិការួមគ្នារបស់បណ្តាដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវគោរពទៅតាមចំណែកដូចបានកំណត់ទៅតាមករណីដែលមានចែងនៅក្នុង ឯកសារក្របខ័ណ្ឌស្តីពីការបង្កើតកន្សោមអាទិភាព។ ក្នុងករណីនេះ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់សមាជិកកន្សោមអាទិភាព ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធធនាគារ ក្រោមរូបភាពបង្វែរសាច់ប្រាក់ពីគណនីគម្រោង ដែលបានព្រមព្រៀងគ្នាដោយរាជរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ទៅក្នុងគណនីផ្ទាល់ខ្លួនរបស់សមាជិកកន្សោមអាទិភាពម្នាក់ៗ ។

មាត្រា ១៦.-

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តសម្រាប់ការអនុវត្តការងារ ដូចបានកំណត់ក្នុងមាត្រា ១៣ និងមាត្រា ១៤ នៃអនុក្រឹត្យនេះ អាចធ្វើការផ្លាស់ប្តូរបាន អាស្រ័យតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ ។

មាត្រា ១៧.-

មន្ត្រីរាជការដែលបានទទួលប្រាក់បំណាច់មុខងារតាមមាត្រា ១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល និងមាត្រា ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ និងបទដ្ឋានពាក់ព័ន្ធផ្សេងទៀត មានកាតព្វកិច្ចជំរុញដំណើរការកន្សោមអាទិភាពឱ្យប្រព្រឹត្តទៅបានល្អប្រសើរតាមការចាត់តាំងរបស់ប្រធានស្ថាប័ន ។ មន្ត្រីទាំងនេះមិនត្រូវបានទទួលប្រាក់ឧបត្ថម្ភពីការអនុវត្តកម្មវិធីកន្សោមអាទិភាពឡើយ លើកលែងតែប្រធានគម្រោងកន្សោមអាទិភាពដែលបានកំណត់ក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ ។

ជំពូកទី៥
ការគ្រប់គ្រងកន្សោមអាទិភាព

មាត្រា ១៨.-

កន្សោមអាទិភាពដែលបង្កើតឡើងដោយក្រសួង ស្ថាប័នសាមី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយផ្ទាល់របស់ក្រសួង ស្ថាប័នសាមី ។

ក្រសួង ស្ថាប័ន ដែលបង្កើតកន្សោមអាទិភាព ត្រូវទទួលខុសត្រូវចំពោះការដាក់ឱ្យដំណើរការកន្សោមអាទិភាព និងធានាចំពោះការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់ការដាក់ឱ្យដំណើរគម្រោងដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ។

មាត្រា ១៩.-

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព អាចផ្តល់ជំនួយផ្នែកបច្ចេកទេសតាមការចាំបាច់ដល់ក្រសួង ស្ថាប័ន ហើយមានសិទ្ធិក្នុងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើដំណើរការអនុវត្តកន្សោមអាទិភាព ។

មាត្រា ២០.-

ក្រសួង ស្ថាប័ន ត្រូវតែងតាំងថ្នាក់ដឹកនាំជាន់ខ្ពស់មួយរូបជានាយកកម្មវិធីកន្សោមអាទិភាព ដើម្បីដឹកនាំសម្របសម្រួល និងតាមដានត្រួតពិនិត្យ ដល់ការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព តាមយុត្តាធិការរៀងៗខ្លួន ។

មាត្រា ២១.-

សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់នាយកកម្មវិធីកន្សោមអាទិភាព ត្រូវកំណត់នៅក្នុងឯកសារក្របខ័ណ្ឌនៃការបង្កើតកន្សោមអាទិភាពនីមួយៗ ស្របតាមឯកសារណែនាំ សម្រាប់ការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព ។

មាត្រា ២២.-

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវទទួលខុសត្រូវចំពោះការសម្របសម្រួលដល់ការបង្កើត ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យកម្មវិធីកន្សោមអាទិភាពនៅតាមក្រសួង ស្ថាប័ននីមួយៗ ។

ទោះបីជាកន្សោមអាទិភាពនីមួយៗមិនមានកំណត់រយៈពេលជាក់លាក់សម្រាប់ការដាក់ឱ្យដំណើរការក្តី ក៏ប៉ុន្តែត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃយ៉ាងហោចណាស់មួយឆ្នាំម្តងៗ ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពការងារ ការពិចារណាគួរបន្តអនុវត្ត និងដាក់ចេញវិធានការសម្រាប់កែលំអប្រសិទ្ធភាពការងារ ។

ជំពូកទី៦

ប្រភពថវិកាសម្រាប់ដំណើរការកន្សោមអាទិភាព

មាត្រា ២៣.-

ថវិកាសម្រាប់ដំណើរការកន្សោមអាទិភាព មានប្រភពមកពី :

- ថវិកាជាតិ
- ថវិកាហិរញ្ញប្បទានពីបណ្តាដៃគូអភិវឌ្ឍន៍ ។

ថវិកាបដិភាគដែលបានមកពីថវិកាជាតិ និងពីបណ្តាដៃគូអភិវឌ្ឍន៍សម្រាប់ធ្វើហិរញ្ញប្បទានដល់កម្មវិធីកន្សោមអាទិភាពនីមួយៗ នឹងត្រូវកំណត់នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ ដោយមានការព្រមព្រៀងគ្នាទាំងសងខាង ។

ជំពូកទី៧

អន្តរប្បញ្ញត្តិ

មាត្រា ២៤.-

កន្សោមអាទិភាពដែលកំពុងដាក់ឱ្យដំណើរការនៅតាមក្រសួង ស្ថាប័ន ត្រូវបន្តអនុវត្តតាមខ្លឹមសារដូចមានចែងនៅក្នុងសេចក្តីសម្រេចក្នុងការបង្កើតកន្សោមអាទិភាពនោះ ហើយការបើកផ្តល់ប្រាក់ឧបត្ថម្ភសមាជិកកន្សោមអាទិភាពទាំងនោះត្រូវអនុវត្តតាមអនុក្រឹត្យនេះក្រោយពេលចូលជាធរមាន ។

ចំពោះកន្សោមអាទិភាពដែលកំពុងដំណើរការ ហើយដែលគ្រោងនឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃឡើងវិញ អាចនឹងត្រូវបានពន្យារពេលប្រសិនបើកន្សោមអាទិភាពនោះស្របទៅនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ។ ការពន្យារពេលត្រូវសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

ជំពូកទី៨

អវសានប្បញ្ញត្តិ

មាត្រា ២៥.-

អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព និងអនុក្រឹត្យលេខ ២០៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលកម្រិតប្រាក់ឧបត្ថម្ភសមាជិកកន្សោមអាទិភាព ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា . ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សុខ អាន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត
- ដូចមាត្រា ២៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរំសាយដែនព្រៃប្រមូលទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ស្ថិតនៅឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតនូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ទំហំសរុបមួយពាន់ប្រាំមួយរយហិកតា (១ ៦០០ហិកតា) ស្ថិតនៅឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានរំសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

មាត្រា ៣.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីសាធារណៈរបស់រដ្ឋទំហំ មួយពាន់ប្រាំមួយរយហិកតា (១ ៦០០ហិកតា) ដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះ ជូនក្រសួងការពារជាតិ(អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ) ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ តាមគោលការណ៍ បទដ្ឋានកំណត់របស់រាជរដ្ឋាភិបាល និងតម្រូវការជាក់ស្តែងចាំបាច់របស់កងទ័ព ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ០៣ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ


ឧបសម្ព័ន្ធនៃ អនុក្រឹត្យលេខ
450
452
454
456
458
460
462
464
466
468
470
472
474
1570
1572
1574
1576
1578
1580
1582
Anlong
សញ្ញាសំគាល់
ព្រៃប្រទល់ស្នើសុំ
ព្រៃប្រទល់តំបន់ព្រៃការពារ
N
W
E
S
មាត្រដ្ឋាន ១ : ៧០ ០០០
2
0
2Km

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤ . អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំសាយដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ស្ថិតនៅឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតនូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ទំហំ បួនរយពីរហិកតា(៤០២ហិកតា) ស្ថិតនៅឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានវិសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

មាត្រា ៣.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីសាធារណៈរបស់រដ្ឋទំហំ បួនរយពីរហិកតា (៤០២ហិកតា) ដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះ ជូនក្រសួងការពារជាតិ(អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ) ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ តាមគោលការណ៍ បទដ្ឋានកំណត់របស់រាជរដ្ឋាភិបាល និងតម្រូវការជាក់ស្តែងចាំបាច់របស់កងទ័ព ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ


ឧបសម្ព័ន្ធនៃ អនុក្រឹត្យលេខ.. ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩
សញ្ញាសំគាល់
ផ្ទៃដីត្រូវកាត់ចេញ
ផ្លូវ
ផ្លូវទឹក
ខ្សែរយៈកំពស់
N
W
E
S
មាត្រដ្ឋាន ១ : ៣០ ០០០
០.៥ 0 ០.៥ គ.ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧៤ - អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ÷

- លោក **កែវ សាមិន**
- លោក **ជា កែវ**

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការពារជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៥៧៥..អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការជូនមេដាយមាសការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ :

ត្រូវបានប្រគល់មេដាយមាសការងារជូនជន ដែលមានស្នាដៃឆ្នើមក្នុង ការបំពេញភារកិច្ច នៅក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១- លោក វិន ប្រុស
២- លោក ជា សួរ
៣- លោក ម៉ាត់ ត្រីយ៉ា
៤- លោក ឌុច សុគន្ធ
៥- លោក ហោ ញ៉េប
៦- លោក ហួន សម្បត្តិ
៧- លោក លី វេងសែ
៨- លោក ជ្រិន វណ្ណេ
៩- លោក វ៉ាន់ វុឌ្ឍី
១០- លោក បេន សំអាត
១១- លោក ពឹង គឹមសួរ
១២- លោក ឌុយ វាសនា
១៣- លោក ជ្រីវ កុសុណា
១៤- លោកស្រី តោ ពិឡា
១៥- លោក ប៉ាវ ហេងតារា
១៦- លោក ស៊ុន ដារ៉ាវន្ត
១៧- លោក ឆាន់ គឹមសឿន
១៨- លោក គឹម ច័ន្ទរស្មី

មាត្រា ២ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តបាត់ដំបង និង អស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៦៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ របស់ក្រសួង បរិស្ថាន ទៅជា អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២ រូបនៃក្រសួងបរិស្ថានដូចមានរាយនាមខាងក្រោម:

១- លោក **មាស សុផល** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

២- លោក **គីម ណុង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូន លោក អ៊ុក ណាវ៉ាន់ ឱ្យបំពេញមុខងារងារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា១ និងមាត្រា២ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានសិទ្ធិចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តអង្គកំនប់ និងវត្តចកអណ្តែត ស្ថិតក្នុងឃុំដូង ស្រុកបាទី ខេត្តតាកែវ ដូចមានព្រះនាម និងនាមខាងក្រោម :-

១-ព្រះតេជគុណ	**លឹម សេងគីម**	គង់នៅវត្តអង្គកំនប់	បច្ច័យ ចំនួន ៣៥.០០០ ដុល្លារ
២-ព្រះតេជគុណ	**នុំ ជា**	គង់នៅវត្តចកអណ្តែត	បច្ច័យ ចំនួន ១៨.០៥០ ដុល្លារ
៣-លោក	**លឹម ឈាងគ្រី**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៣០.៥០០ ដុល្លារ
៤-លោក	**អ៊ឹង អៀង**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២១.៥០០ ដុល្លារ
៥-លោក	**លី ហ៊ាន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៣៥.០០០ ដុល្លារ
៦-លោក	**សោម ឈាងឃុន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១៥.០០០ ដុល្លារ
៧-លោក	**ទើង សុខ**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២០.០០០ ដុល្លារ
៨-លោក	**លឹម ឈាងគួន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២០.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦៧ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគថវិកាជួយកសាងសាលាធម្មសភា នៅវត្តអង្គជុំ ស្ថិតក្នុងឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ ចំនួន ៥១.៩១៥ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-លោក **គោគ សំឡេង** សប្បុរសជននៅប្រទេសកាណាដា

២-អ្នកស្រី **ឡឹច ឡេងគី** សប្បុរសជននៅប្រទេសកាណាដា

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៩. អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមជួយកសាងសាលាបាលី កុដិ ឈាបនដ្ឋាន ផ្លូវ បង្គន់អនាម័យ បាសាំងទឹក និងឈូសឆាយពង្រាបដី នៅវត្តព្រៃនប់ ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះចៅអធិការ	**ប៉ុណ្ណ សុវណ្ណា**	បច្ច័យ ចំនួន ១០.៣៥០ ដុល្លារ
២-លោកជំទាវ	**ស៊ាន ឈុនហេង ស្បោង សារ៉ាត**	ថវិកា ចំនួន ១០.២៥០ ដុល្លារ
៣-លោកជំទាវ	**ឡូ គីម** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី	ថវិកា ចំនួន ១០.១៥០ ដុល្លារ
៤-លោក	**កែ សុខន**	ថវិកា ចំនួន ១០.១៥០ ដុល្លារ
៥-អ្នកស្រី	**កែប សម្បត្តិ**	ថវិកា ចំនួន ១០.១១៥ ដុល្លារ
៦-អ្នកស្រី	**នុច ចន្ថា**	ថវិកា ចំនួន ១០.០២៥ ដុល្លារ
៧-លោក	**ទូច សើចន្ទន**	ថវិកា ចំនួន ១០.០៥០ ដុល្លារ
៨-លោក	**ជា ណារឿន**	ថវិកា ចំនួន ១០.០២០ ដុល្លារ
៩-លោក	**ម៉ែន សំបូរ**	ថវិកា ចំនួន ១០.០៨០ ដុល្លារ
១០-លោក	**ឡឹង មេន**	ថវិកា ចំនួន ១០.០២០ ដុល្លារ

/

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក **អន ប៊ុន** ថវិកា ចំនួន ៨.៣០០ ដុល្លារ

២-លោក **ម៉ៅ ធន់** ថវិកា ចំនួន ៨.៤០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និងអភិបាលខេត្តព្រះសីហនុ ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧០ .អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប ដែលបានបរិច្ចាគធនធានជួយកសាងអគារសិក្សា ០១ខ្នង មាន០៦បន្ទប់ និងដាក់ឈ្មោះថា : សាលាបឋមសិក្សាសាមគ្គីខ្មែរ-បារាំង-អូទ្រីស-ស្វីស ស្ថិតក្នុងឃុំកូនសត្វ ស្រុកកំពត ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

១-លោក MASUREL FRANCIS សប្បុរសជន នៅប្រទេសបារាំង បានឧបត្ថម្ភថវិកា ចំនួន ២០.៨០០ ដុល្លារ

២-លោក **រស់ ហឿន** សប្បុរសជន នៅប្រទេសស្វីស ថវិកា ចំនួន ២០.០០០ ដុល្លារ

៣-លោក **សោម ស៊ុនស្រេង** សប្បុរសជន នៅប្រទេសបារាំង ថវិកា ចំនួន ១២.០០០ ដុល្លារ

៤-លោក **អ៊ុម សាម៉ាថារ៉ា** សប្បុរសជន នៅប្រទេសអូទ្រីស ថវិកា ចំនួន ១២.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៧២...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៩ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រី និយោជិត នៃរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ ចំនួន២៤រូប ដែលមានស្នាដៃល្អក្នុងកិច្ចដំណើរការ សាងសង់រោងចក្រផលិតទឹកស្អាតជ្រោយចង្វារ ដំណាក់កាលទី២ និង ការផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដូចមានរាយនាមខាងក្រោម :-

១-	លោក	កែវ	សុវណ្ណរិទ្ធ	អគ្គនាយករង
២-	លោក	ឡុង	ណារ៉ូ	អគ្គនាយករង
៣-	បណ្ឌិត	ជា	វិសុទ្ធ	ជំនួយការអគ្គនាយក
៤-	លោក	ស៊ឹម	ខេមលីន	ប្រធាននាយកដ្ឋានអាជីវកម្ម
៥-	លោក	រស់	គីមលាង	ប្រធាននាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ
៦-	លោក	សិរិទ្ធ	សុវិទ្យា	ប្រធាននាយកដ្ឋានផែនការ-គំរោង
៧-	លោក	ឃុត	ធុរ្យារិទ្ធ	ប្រធាននាយកដ្ឋាន ផលិតកម្ម និងផ្គត់ផ្គង់ទឹក
៨-	លោកស្រី	ធឿន	ណារី	ប្រធាននាយកដ្ឋាន រដ្ឋបាល និងធនធានមនុស្ស
៩-	លោក	ឡាច	បដ្ឋណា	អនុប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ
១០-	លោក	ជា	សតិគន្ធ	អនុប្រធាននាយកដ្ឋាន ផែនការគំរោង
១១-	លោកស្រី	ចិន	ចន្ទ្រា	អនុប្រធាននាយកដ្ឋាន អាជីវកម្ម
១២-	លោក	ម៉ា	ណូរ៉ាទីន	អនុប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក
១៣-	លោក	មៀច	សារិន	ប្រធានការិយាល័យផលិតកម្ម
១៤-	លោក	សេក	សំអាន	ជំនួយការនាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក
១៥-	លោក	គង់	សុន្ទារ៉ា	ប្រធានរោងចក្រជ្រោយចង្វារ
១៦-	លោក	ឌុយ	ប៊ុនសេរីរិទ្ធ	អនុប្រធានការិយាល័យសិក្សាគំរោង

១៧-	លោក	**យ៉ា**	**វណ្ណធឿន**	អនុប្រធានផលិតទឹកជ្រោយចង្វារ
១៨-	លោក	**កែវ**	**ហេង**	ប្រធានផ្នែកពិសោធន៍ទឹក ការិយាល័យផលិតកម្ម
១៩-	លោក	**មាស**	**ថន**	ប្រធានក្រុមដាក់បំពង់ ការិយាល័យបណ្តាញមេ
២០-	លោកស្រី	**ត្រី**	**វណ្ណា**	ប្រធានក្រុមផ្នែកពិសោធន៍ទឹក ការិយាល័យផលិតកម្ម
២១-	លោកស្រី	**គី**	**មុនីចរិយា**	ប្រធានក្រុមផ្នែកពិសោធន៍ទឹក ការិយាល័យផលិតកម្ម
២២-	លោកស្រី	**យិន**	**ចាន់លី**	និយោជិតផ្នែកពិសោធន៍ទឹក ការិយាល័យផលិតកម្ម
២៣-	លោក	**យ៉ែម**	**កុសល**	ប្រធានក្រុមគ្រប់គ្រងតំបន់ ការិ.គ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក
២៤-	លោក	**ម៉ើន**	**ឈាង**	ប្រធានក្រុមគ្រប់គ្រងតំបន់ ការិ.គ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៧២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៦ នាក់ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **ឌុច ចាន់ថន** អត្តលេខ ០១០៤៦

២-លោកវរសេនីយ៍ទោ **អ៊ុក ប៊ុនសាន** អត្តលេខ ០១៩៩៥

៣- លោកវរសេនីយ៍ទោ **ទិម ស៊ីធុត្យា** អត្តលេខ ០២៦៤២

៤- លោកវរសេនីយ៍ទោ **អ៊ុច ធីរៈ** អត្តលេខ ០១៣៥២

៥- លោកវរសេនីយ៍ទោ **អ៊ុន ប៊ុនធុល** អត្តលេខ ៥៦៤៧៤

៦- លោកវរសេនីយ៍ទោ **កែច ចាន់ណូ** អត្តលេខ ០២២៣១ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល :__

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៣.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោកស្រី **នឹង គីមស្រេង** ជាទីប្រឹក្សាក្រសួងពត៌មាន មានឋានៈស្មើអគ្គនាយករង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះឱ្យបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ចាម

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗនៅវត្តសិរីអម្ពវ័ន្ត ស្ថិតក្នុងឃុំព្រៃចារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ឧត្តមសេនីយ៍ទោ **ឆិត សារ៉ាត់** អត្តលេខ ០៨២២ នៅរាជធានីភ្នំពេញ ថវិកា ចំនួន ១០.០៩៥ ដុល្លារ

២-អ្នកស្រី **សេង គាង** នៅរាជធានីភ្នំពេញ ថវិកា ចំនួន ១៣.៨០៨ ដុល្លារ

៣-លោក **ឡាយ គាតឡេង** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១០.២០៥ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-វរសេនីយ៍ឯក **យស ផន** អត្តលេខ០៥៨៩ នាយកសាលានគរបាលជាតិភូមិភាគ៥ ថវិកាចំនួន ៥.២៥០ ដុល្លារ

២-វរសេនីយ៍ឯក **ហេង ម៉ុន** អត្តលេខ០៩៩៨ នាយកសាលានគរបាលជាតិភូមិភាគ២ ថវិកាចំនួន ៥.៣០០ដុល្លារ

គ_មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក **ខៃ តូសនិត** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣.២៥០ ដុល្លារ

២-លោក **ផេង ហេង** ឃុំស្រម៉រ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ថវិកាចំនួន ២.៥០០ ដុល្លារ

៣-លោក **អ៊ី ណៃ** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.៧៣០ ដុល្លារ

៤-លោក **រឹម ដារ៉េត** បញ្ជាការវរៈការពារព្រំដែនគោកលេខ ៩១១ ថវិកាចំនួន ២.៧២០ ដុល្លារ

៥-លោក **ខៃ សុវ៉ៃ** គណៈកម្មការវត្តសិរីអម្ពវ័ន្ត ថវិកាចំនួន ២.៩០០ ដុល្លារ

៦-លោក **នូ ចក់** គណៈកម្មការវត្តសិរីអម្ពវ័ន្ត ថវិកាចំនួន ២.៥០០ ដុល្លារ
៧-លោក **ហង្ស តន** អាចារ្យវត្តសិរីអម្ពវ័ន្ត ថវិកាចំនួន ២.៣០០ ដុល្លារ
៨-លោក **ម៉េង ម៉ុន** អាចារ្យវត្តសិរីអម្ពវ័ន្ត ថវិកាចំនួន ១.៧៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៥.អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សយ សុភារ៉ា** ជាជំនួយការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ— កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៤...អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខតំណែង និងតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោកឧត្តមសេនីយ៍ត្រី ចេន ចាន់តុង អត្តលេខ ០១៦១ អនុប្រធាននាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស ទៅជាប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ចរសេនីយ៍ឯក ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ ម៉ែ ស៊ីខេងវ៉ាន់ឌី អត្តលេខ ៦២៧២២
២-លោកស្រីវរសេនីយ៍ទោ អ៊ុំ លក្ខិណា អត្តលេខ ០៤៨៨៨
៣-លោកវរសេនីយ៍ទោ កែវ ភារាពន្លឺ អត្តលេខ ០១៤៧៥
៤-លោកវរសេនីយ៍ទោ ខៀវ ដារ៉ារ័ត្ន អត្តលេខ ០៥០៩៥

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧៧-អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រី មន្ត្រីរាជការស៊ីវិល ចំនួន ១៩ រូបដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិបានល្អ ដូចមានរាយនាមខាងក្រោម :

១-លោក	ខឹម ឈុំ	មន្ត្រីចូលនិវត្តន៍ស្រុកមេសាង
២-លោក	ខឹម សារិន	សមាជិកក្រុមប្រឹក្សាឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
៣-លោក	ឃី យ៉េង	សមាជិកក្រុមប្រឹក្សាឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
៤-លោក	ទ៉ោ សាយ៉ុន	សមាជិកក្រុមប្រឹក្សាឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
៥-លោក	ចុំយ យ៉ុន	សមាជិកក្រុមប្រឹក្សាឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
៦-លោក	ខៅ ឃន	សមាជិកក្រុមប្រឹក្សាឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
៧-លោក	ម៉ី សឿន	សមាជិកក្រុមប្រឹក្សាឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
៨-លោក	ខៃ ឆាំ	សមាជិកក្រុមប្រឹក្សាឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
៩-លោក	អោម អាត	មេបញ្ជាការរងផ្នែកសឹករងស្រុកមេសាង ខេត្តព្រៃវែង
១០-លោក	សួន ហ៊ាន	មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកមេសាង ខេត្តព្រៃវែង

១១-លោក ឈាង លី មន្ត្រីសាលាស្រុកមេសាង ខេត្តព្រៃវែង
១២-លោក ភួង ភន មន្ត្រីសាលាស្រុកមេសាង ខេត្តព្រៃវែង
១៣-លោក ធេព សារ៉េត ប្រធានការិយាល័យកសិកម្មស្រុកមេសាង ខេត្តព្រៃវែង
១៤-លោក យ៉ន យ៉ុន ប្រធានមណ្ឌលសុខភាពឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង
១៥-លោក កែវ កុល ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំច្រេស ស្រុកមេសាង
១៦-លោក យឹម ស៊ីន នាយកវិទ្យាល័យចន្ទត្រីះស្នា
១៧-លោក ហ៊ុត សំរាម នាយកសាលាបឋមសិក្សាជ័យមង្គល
១៨-លោក សេន ណារ៉ាក នាយកសាលាបឋមសិក្សាព្រហ៊ារ
១៩-លោក គង់ សុភារិន ប្រជាពលរដ្ឋភូមិពោន ឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៨ - អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០1 ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនអស់លោកកងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ ចំនួន ១១ រូប ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចជូនជាតិបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

ក. **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះ :

១-លោកស្រីវរសេនីយ៍ឯក **សុខ សម្បត្តិ** អនុប្រធាននាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន ក្រសួងមហាផ្ទៃ

២-លោកស្រីវរសេនីយ៍ឯក **ជាំ ពុធថាវី** ក្រសួងការពារជាតិ

៣-លោក **ភិ គីមសាន្ត** ជំនួយការឯកឧត្តម **ហួន ចន្ទភក្តជា** អគ្គាធិការរងក្រសួងមហាផ្ទៃ

៤-លោក **អ៊ុំ ភិរិយា** ជំនួយការឯកឧត្តម **ហួន ចន្ទភក្តជា** អគ្គាធិការរងក្រសួងមហាផ្ទៃ

៥-លោក **ជា ឡុក** ជំនួយការឯកឧត្តម **ហួន ចន្ទភក្តជា** អគ្គាធិការរងក្រសួងមហាផ្ទៃ

៦-លោក **ហួន ចាន់ខាសនា** អធិការរង នៃអធិការដ្ឋាននគរបាលខណ្ឌទួលគោក

៧-លោក **គង់ សុខសាន្ត** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ក្រសួងមហាផ្ទៃ

ខ. **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនចំពោះ :

១-លោក **យូ ទី** អភិបាលរងក្រុងខេមរភូមិន្ទ ខេត្តកោះកុង

២-លោក **សាត់ សុធី** អភិបាលរងស្រុកកំពង់លាវ ខេត្តព្រៃវែង

គ~ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ :

១-លោក ឌួន ភុន មេឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង

២-លោក ស្រី អាចារ្យ ប្រធានមន្ទីរពេទ្យស្រុកមេសាង ខេត្តព្រៃវែង

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ផ្តល់ជូនសប្បុរសជនទៅក្នុង និងក្រៅប្រទេស ចំនួន ១៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ កុដិថ្ម ០១ខ្នង កុដិឈើ ០១ខ្នង វេទិកាបុណ្យ ០១ខ្នង រោងទទួលភ្ញៀវ ០១ខ្នង រោងបាយ ០១ខ្នង ចាក់សាបជុំវិញព្រះវិហារ ខ្លោងទ្វារ ជីកស្រះទឹក ដែលមានទទឹង ២៥ម៉ែត្រ បណ្តោយ ១០០ម៉ែត្រ ចាក់ដីក្នុងទីធ្លាវត្ត សួនច្បារក្នុងវត្ត រោងម៉ាស៊ីនភ្លើង និងបង្គន់អនាម័យ ០១ខ្នង មាន ០៦បន្ទប់ នៅវត្តអង្គម្រះព្រៅ ស្ថិតក្នុងឃុំដូនយ៉យ ស្រុកឈូក ខេត្តកំពត ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

ក. មេដាយមាសស្ថាបនាជាតិចំនួន ០៤ គ្រឿង ប្រគេន និង ផ្តល់ជូន :

១-ព្រះតេជគុណវីរិយបញ្ញោ **សាំង សុន្ធារ៉ា** ព្រះចៅអធិការវត្តអង្គម្រះព្រៅ បច្ច័យចំនួន ១១.១២០ ដុល្លារ

២-ឧបាសក **ធ្រាង ផុន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៥.៨០០ ដុល្លារ

៣-លោក **អួត ស៊ីម្មុត** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.៦០០ ដុល្លារ

៤-លោក **កែម ធឿង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៩ គ្រឿង ប្រគេន និងផ្តល់ជូន :

១-ព្រះតេជគុណអគ្គបណ្ឌិត **សំ យុន** គង់នៅប្រទេសថៃ បច្ច័យចំនួន ៥.៦៧០ ដុល្លារ

២-លោក **កែវ ជឹម** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.៨២០ ដុល្លារ

៣-លោក **ចាច់ សុខ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.៥០០ ដុល្លារ

៤-លោក ភ្នំ សុផាត	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	៥.៣៧៥ ដុល្លារ
៥-លោក ថ្លាង ថ្មរាភដ	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកាចំនួន	៥.១៥០ ដុល្លារ
៦-ឧបាសក ខេង ត្រឹង	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកាចំនួន	៥.០៥០ ដុល្លារ
៧-លោក ហាស់ សំអឿន	សប្បុរសជននៅខេត្តកំពត	ថវិកាចំនួន	៥.០០០ ដុល្លារ
៨-លោក ស្វាយ ផាត	សប្បុរសជននៅខេត្តកំពត	ថវិកាចំនួន	៥.០០០ ដុល្លារ
៩-ឧបាសក ចិត ឆៃ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	៥.០០០ ដុល្លារ

គ. មេដាយសេរីវឌ្ឍនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :

១-ឧបាសក ទន់ តេង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	១.២០០ ដុល្លារ
២-ឧបាសក ស្រី ស៊ុក	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	១.១៤០ ដុល្លារ
៣-លោក កែវ តុន	សប្បុរសជននៅខេត្តកំពត	ថវិកាចំនួន	១.០២០ ដុល្លារ

មាត្រា ២.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ចាម

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន០២រូប ដែលមានគុណបំណាច់ និងស្នាដៃល្អក្នុងការចូលរួមកសាងសមិទ្ធផលនានា នៅវត្តសិរីអម្ពវ័ន្ត ឃុំព្រៃចារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១-លោក **ជៀប គីអឿន** ហៅ **ហាក់ អឿន** នៅភូមិស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម បរិច្ចាគថវិកា ចំនួន ៧២.៣៧០ ដុល្លារ ។

២-ឧបាសិកា **ហាក់ អួន** នៅភូមិស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម បរិច្ចាគថវិកា ចំនួន ៥៨.៣២០ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥២១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងសាលាធម្មសភា និងសមិទ្ធផលផ្សេងៗទៀត នៅវត្តក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**មាស ចាន់**	ព្រះចៅអធិការវត្ត ក្រាំងលាវ	បច្ច័យចំនួន ១០.៥០០ ដុល្លារ
២-លោក	**ឆិត ផូ**	សប្បុរសជនខ្មែរនៅប្រទេសអូស្ត្រាលី	ថវិកា ចំនួន ១៤.៦៥០ ដុល្លារ
៣-អ្នកស្រី	**យ៉េន ណារុន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១២.២៥០ ដុល្លារ
៤-ឧបាសិកា	**ប៊ូ ស៊ីក**	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១២.០០០ ដុល្លារ
៥-លោក	**ថោង ស៊ីម**	មេឃុំក្រាំងលាវ	ថវិកា ចំនួន ១០.២៥០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧបាសក	**ឈឹម ឡេង**	ប្រធានគណៈកម្មការវត្តអណ្តូងប្រេង	ថវិកាចំនួន ៦.២១០ ដុល្លារ
២-ឧបាសក	**ញ៉ឹម ជា**	អាចារ្យវត្តក្រាំងលាវ	ថវិកាចំនួន ៥.៤៥០ ដុល្លារ
៣-ឧបាសក	**ម៉ៅ ប៉េត**	អាចារ្យវត្តក្រាំងលាវ	ថវិកាចំនួន ៥.២០០ ដុល្លារ
៤-ឧបាសក	**អ៊ុំ អ៊ីន**	គណៈកម្មការវត្តក្រាំងលាវ	ថវិកាចំនួន ៥.១២០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៨៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **ឃុយ ហៀង** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានគមនាគមន៍និងប្រៃសណីយ៍ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង ឧបដ្ឋានសាលា ០១ខ្នង ទំហំ ៤០ម៉ែត្រ គុណ ២០ម៉ែត្រ ធ្វើអំពីថ្មប្រក់ក្បឿង នៅវត្តប្រាសាទស្រះឈ្នួរ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ឡុង អែ**	ព្រះចៅអធិការវត្តប្រាសាទស្រះឈ្នួរ	បច្ច័យចំនួន ១១.៣០០ ដុល្លារ
២-ព្រះតេជគុណ	**អ៊ុម សំណាង**	គ្រូសូត្រស្តាំ វត្តប្រាសាទស្រះឈ្នួរ	បច្ច័យចំនួន ១២.៥០០ ដុល្លារ
៣-ឧបាសក	**អ៊ុច មាស**	នៅខេត្តបន្ទាយមានជ័យ	ថវិកា ចំនួន ១៣.១០០ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧបាសក	**ចាន់ ថាត់**	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកា ចំនួន ៥.៥០០ ដុល្លារ
២-ឧបាសក	**ប៉ែន ហ៊ន**	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកា ចំនួន ៥.៣០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក Peter Godwin ទីប្រឹក្សាបច្ចេកទេស នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែកនិងកាមរោគ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៦ ដោយបានខិតខំយកចិត្តទុកដាក់ផ្តល់ជំនួយឧបត្ថម្ភជាបន្តបន្ទាប់ និងគាំទ្រដោយឥតងើយហត់ក្នុងការបង្កើនសមត្ថភាពការងារ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងការបង្ការការរាលដាលមេរោគអេសដ៍ ថែទាំអ្នកជម្ងឺអេសដ៍ និងអ្នកផ្ទុកមេរោគអេសដ៍ អោយកាន់តែមានគុណភាពខ្ពស់ សរុបថវិកាចំនួន ២៨.៦លាន ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ៕

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៩

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សរឫទ្ធិ** ជូនលោក **ឡុច សារិន** ប្រធាននាយកដ្ឋានរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច កន្លងមក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៧ សសរ

សេចក្តីសម្រេច

ស្តីពី

ការតែងតាំងសមាជិកភាពថ្មី ជំនួសសមាជិកភាពចាស់ នៃសមាជិក សមាជិកា គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែល ប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើត គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ ១១ សសរ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការតែងតាំង សមាសភាពសមាជិក សមាជិកា នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

សម្រេច

ប្រការ១: ត្រូវបានតែងតាំងជាសមាជិកភាពថ្មីជំនួសសមាជិកភាពចាស់នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃ ស្ត្រី និងគ្រួសារខ្មែរ ក្នុងស្ថាប័នរដ្ឋមួយចំនួន ក្នុងប្រការ ១នៃសេចក្តីសម្រេច លេខ ១១ សសរ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៧ ស្តីពីការតែងតាំង សមាសភាពសមាជិក សមាជិកា នៃគណៈកម្មាធិការជាតិលើក កម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដូចខាងក្រោម:

១-លោកជំទាវ **ស៊ុំ ជេហ៊ីន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី ជាអនុប្រធានអចិន្ត្រៃយ៍ ជំនួស លោកជំទាវ **យូ អយ** បច្ចុប្បន្នជាឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុ ប្រចាំនៅប្រទេសថៃឡង់

២-លោកជំទាវ **ម៉ិញ កុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអនុប្រធាន ជំនួសឯកឧត្តម **ហ៊ឹម ឆែម** បច្ចុប្បន្ន រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

៣-លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន ជំនួសឯកឧត្តម **ទេព នុន្នរី** បច្ចុប្បន្ន រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី

៤-លោកជំទាវ **សុខ ចិន្តាឡាយ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកាជំនួសលោកជំទាវ **ឈឹម ណាឡា**

៥-ឯកឧត្តម **ឈាង ឆាត់** អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក ជំនួសឯកឧត្តម **ប៉ុណ ម៉េងហួរ** បច្ចុប្បន្នអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍

៦-លោកជំទាវ **ឆន់ សារ៉ឹម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិកា ជំនួស ឯកឧត្តម **ប៊ួយ ប៊ុណ្ណា**

៧-លោកជំទាវ **សម មុន្នីកា** អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ជាសមាជិកា ជំនួស លោកជំទាវ **កង បូរាណ**

៨-អ្នកអង្គម្ចាស់ **ណឹម សូហ៊ីន** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ជាសមាជិកា ជំនួស លោកជំទាវ **ស៊ី ជេហ៊ីន** បច្ចុប្បន្នរដ្ឋលេខាធិការក្រសួងកិច្ចការនារី

៩-ឯកឧត្តម **ឃាត់ ប៊ុនធឿន** អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា ជាសមាជិក ជំនួស ឯកឧត្តម **យិន លួត**

១០-ឯកឧត្តមឧត្តមសេនីយ៍ឯក **ស្វរ ឌន** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ ជាសមាជិក ជំនួស ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** បច្ចុប្បន្នអគ្គស្នងការ នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ

ប្រការ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែង ក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ :[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០[illegible]

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៥១៩/០៩ គ.វ.ក ចុះថ្ងៃទី១៨.០៣.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន បាសធើរ ប្រេនតុន (ខេមបូឌា) ខូនីង មេនូហ្វេកឈ័ររីង ចុះថ្ងៃទី១២.០៣.២០០៩

សំរេច

ប្រការ១ :

- អនុញ្ញាតឱ្យក្រុមហ៊ុន បាសធើរ ប្រេនតុន (ខេមបូឌា) ខូនីង មេនូហ្វេកឈ័ររីង តំណាងដោយ លោក THANA-KARNJANASUTHI KONGKIAT សញ្ជាតិថៃ អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ Z076416 ចុះថ្ងៃទី ១២.០៥.២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន : Bangkok, Thailand ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម :

ល.រ ឈ្មោះផលិតផល លេខចុះបញ្ជីផលិតផល ISIC Code

១- សម្លៀកបំពាក់ **៣២២០**

-ផ្លាកឈ្មោះ រោងចក្រ : " **បាសធើរ ប្រេនតុន (ខេមបូឌា) ខ្លូធីង មេនូហ្វេកឈ័ររីង (BAXTER BRENTON (CAMBODIA) CLOTHING MANUFACTURING CO., LTD.)**"

-ទីតាំងរោងចក្រ : "***ភូមិព្រៃពាំងថ្លៃ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ***"

ប្រការ២ :

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣ :

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤ :

ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។/.

ប្រការ៥ :

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

ប្រការ៦ :

ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

ប្រការ៧:

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ជិកាម្មរោងចក្រប្រចាំ ០៣ឆ្នាំ។

ប្រការ៨ :

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩ :

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករានៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០:

រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

ប្រការ១១:

លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

ប្រការ១២:

ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣:

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗបារិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

ប្រការ១៤:

ប្រកាសលេខ ៥៦៦ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១១.០៧.២០០៣ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ហ្វាញជីស (ខេមបូឌា) ដែលមានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥:

អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

ប្រការ១៦:

ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
inistry of Industry, Mines and Energy
លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០០៩

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

